Reading Book

ពិភពរឿងនិទាន

The World of Stories

រឿង នាងពៅសក់ក្រអូប

Fragrant-Haired Neang Pov




M.05

សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge


នាងពៅ ជានារីម្ចាក់មានរូបសម្ផស្សស្រស់សោភាថែមទាំងមានសក់ក្រអូបទៀតផង។ ប្តីរបស់នាងជាអ្នកជំនួញ។ ពួកគេទាំងពីរនាក់រស់នៅក្បែរមាត់ស្ទឹងដាច់ឆ្ងាយពីគេ។ មុននឹងប្តីចេញទៅជួញក៏បានផ្តាំប្រពន្ធថា "អូនសម្លាញ់ ! បងទៅរកស៊ីយូរណាស់ បើអូននឹកបង អូនផ្តាច់សរសៃសក់ដាក់ក្នុងកន្ទោង ហើយបណ្តែតតាមទឹកស្ទឹងនេះទៅ ពេលបងឃើញបងនឹងវិលមកជួបអូនជាក់ជាពុំខាននឡើយ"។

Neang Pov not only was beautiful, but also had fragrant hair. Her husband was a merchant. The spouses lived near the streamside far away from the others. Before going out to do his business, her husband told her, "my darling I will be away on business for quite a long time, so if you miss me, you should cut off several of your strands of hair, put them in a Kantaung (a Kantaung is a type of bowl made from leaves and used for storing offerings to the spirit) and float it along the stream current. When I see it, I will definitely come back to meet you."



លុះផ្តែផ្តាំសព្វគ្រប់ហើយបុរសជាប្តី **នាងពៅសក់ក្រអូប** ក៏លាប្រពន្ធចេញទៅ។ លុះយូរថ្ងៃខែមិនឃើញប្តីត្រឡប់មកវិញ **នាងពៅ** ក៏ធ្វើកន្ទោងមួយហើយផ្តាច់សរសៃសក់ដាក់ក្នុងកន្ទោងបណ្តែតតាមទឹកស្ទឹងនោះ។

After telling her this, Fragrant-Haired Neang Pov's husband said farewell to his wife. Many months went by and she didn't see her husband's return. So Neang Pov made a Kantaung, cut off some strands of her hair, put them in the Kantaung, and finally floated it along the stream current.




មានពួកចោរព្រៃមួយក្រុមកំពុងងូតទឹកស្ទឹងស្រាប់តែមានក្លិនក្រអូបចំឡែក មេចោរបានប្រទះឃើញកន្ទោងមួយអណ្តែតលើទឹកក៏ហែលទៅយកកន្ទោងនោះ ក៏ឃើញមានសក់វែងហើយក្រអូបទៀតផង ទើបដឹងថាប្រាកដជាសក់របស់មនុស្ស ស្រីហើយក៏ធ្វើដំណើរបញ្ច្រាស់ទឹកស្ទឹង ដើម្បីទៅរកម្ចាស់សក់ក្រអូប។

A group of forest robbers that was bathing in the stream smelled a fragrant whiff. At that time, the robber boss saw a Kantaung floating and he swam to get the Kantaung. He saw some long and fragrant hairs. He assumed that the hair belonged to a woman, so he swam up against the stream current to find the fragrant hair owner.


មិនយូរប៉ុន្មានក៏មកដល់ផ្ទះ **នាងពៅសក់ក្រអូប** នោះមែន។ គ្រាន់តែឃើញ
សម្រស់ដ៏ស្រស់ស្អាតខុសប្លែកពីស្រីដទៃ មេចោររូបនេះក៏ចាប់ចិត្តប្រតិព័ទ្ធលើ
រូបនាងយ៉ាងខ្លាំងក៏សុំសេចក្តីស្នេហាពីនាង។ ទោះបីមេចោរខំអង្វរលួងលោម
យ៉ាងណាក៏ដោយ ក៏**នាងពៅ** មិនព្រមស្រលាញ់មេចោរនោះដែរ។

Before long, he reached Neang Pov's house. He saw that Neang Pov was the most beautiful woman of all, so he fell deeply in love with her. He tried to flirt with her, but no matter how hard he tried, she still refused to love the robber boss.





មេចោរខឹងខ្លាំងណាស់ក៏ចាប់នាងទៅជាមួយ។ ជួនជាចៃដន្យប្តី **នាងពៅ** ត្រឡប់មកផ្ទះមិនឃើញប្រពន្ធក៏ឡើងជិះសេះតាមរកនាង។ លុះដល់កណ្តាលព្រៃ ជ្រៅបុរសជាប្តីស្រែកហៅប្រពន្ធថា "**ពៅ** អូន! **ពៅសក់ក្រអូប** អូននៅឯណា?" សំឡេងនេះក៏បានឮទៅដល់ **នាងពៅ** ហើយឆ្លើយតបវិញថា "ជួយខ្ញុំផង..."។

The robber boss got extremely furious, so he decided to kidnap her from her house. When Neang Pov's husband came back home, he did not see his wife. He rode his horse away to find his wife immediately. When he reached the forest center, Neang Pov's husband called out his wife, "My dear Pov! My fragrant-haired Pov, where are you?" Soon, the call was heard by Neang Pov, so she replied, "Help me!"



បន្ទាប់មកប្តីក៏បានឃើញប្រពន្ធកំពុងនៅជាមួយមេចោរ ហើយក៏ស្ទុះទៅជួយនាងភ្លាម។ គ្រានោះមេចោរបានចាក់មួយកាំបិតចំដើមទ្រូងប្តីនាងស្លាប់មួយរំពេច **នាងពៅ** ឃើញដូច្នេះក៏ស្រែកទ្រហោយំអោបសពប្តីហើយបួងសួងក្នុងចិត្តថា "សូមទេវតាអារក្សអ្នកតារក្សាព្រៃភ្នំព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយ សូមជួយថែរក្សាកុំឱ្យមានសត្វអ្វីមកស៊ីសពប្តីនាងខ្ញុំឱ្យសោះ"។






At that time, when he saw his wife with the robber boss, Pov's husband rushed to save her. At that moment, the robber boss took out his knife and stabbed Pov's husband in the chest, causing immediate death of Pov's husband. Seeing this, Neang Pov wept, holding her husband's body and prayed, "Divinities, guardian spirits of hills and woods, and other sacred things, help protect my husband's body so that no animal can eat my husband's body."

បួងសួងចប់នាងក៏លួចដកកូនកាំបិតលាក់ទុកជាប់នឹងខ្លួន ហើយក៏ព្រមទៅជាមួយមេចោរនោះ។ **នាងពៅ** សុំអង្វរមេចោរឱ្យដឹកសេះដើរពីមុខ ហើយនាងឡើងជិះសេះតែម្ដាក់ឯងតាមក្រោយ។ ហេតុតែមេចោរស្រលាញ់នាងខ្លាំងពេក គេព្រមធ្វើតាមនាងគ្រប់បែបយ៉ាងទាំងអស់។ នៅពេលកំពុងធ្វើដំណើរ **នាងពៅ** ក៏លួចរោយគ្រាប់ត្រសក់ស្រូវតាមផ្លូវរហូត។

After completing her prayer, she secretly took out a small knife and carried it with her. She then agreed to go with the robber boss. Neang Pov begged the robber boss to lead the horse in front of her and she rode on the horse alone. Because he adored her so much, he agreed to all her requests. While traveling, Neang Pov secretly dropped melon seeds along the way.




លុះអស់គ្រាប់ត្រសក់ស្រូវ **នាងពៅ** ក៏និយាយពាក្យផ្អែមល្អែមទៅកាន់មេចោរ ថា "អ្នកអើយ ! ខ្ញុំចង់ឈប់សម្រាកមួយភ្លែត ព្រោះខ្ញុំអាណិតអ្នកខ្លាំងណាស់ ! មើលទៅអ្នកប្រាកដជានឿយហត់ណាស់ហើយ សូមអ្នកជួយដាក់ខ្ញុំចុះបន្តិចមក" មេចោរសើចឆ្លើយថា "ល្អណាស់ ! ចាំបងជួយ"។

When the melon seeds ran out, Neang Pov sweetly talked to the robber boss, "You! Now, I would like to have some rest because I feel pity for you! You look so exhausted; please help me off the horse." The robber boss quickly responded, "Great! I'll help."


ឆ្លៀតពេលមេចោរមិនប្រយ័ត្នខ្លួន **នាងពៅ** ក៏ដកកូនកាំបិតចាក់មេចោរនោះ ស្លាប់បាត់ទៅ។ **នាងពៅ** ម្ដីម្ដាដើរយ៉ាងលឿនត្រឡប់មករកប្ដី ប៉ុន្តែតាមផ្លូវដែល មានគ្រាប់ត្រសក់ស្រូវ បែរជាដុះមានផ្លែផ្កាមីដេរដាសពាសពេញផ្លូវទៅវិញ។

To take advantage when the robber boss was not paying attention, Neang Pov took out the small knife and stabbed the robber boss to death. Neang Pov rushed to see her husband's body; but, along the way on which the melon seeds had been dropped, there were melon plants which bearing a lot of fruit and blossoms and which grew densely along the way.




មកដល់កន្លែងសាកសពមានទេវតាពីររូបតំណែងខ្លួនជាសត្វពស់ និងសត្វស្កា កំពុងប្រយុទ្ធគ្នារហូតដល់សត្វស្កាខាំពស់ស្លាប់។ សត្វស្កាក៏ទំពាសំបកឈើក្បែរនោះ មកព្រួសលើសត្វពស់ ពេលនោះពស់ក៏រស់ឡើងវិញហើយរលាយខ្លួនបាត់ទៅ។

Reaching the place where the body lied, there were two divinities disguised themselves as a snake and a meerkat. The two animals were fighting with each other until the meerkat bit the snake to death. The meerkat chewed some barks from the nearby tree and spat on the dead snake, and the snake came to life again and they both vanished.



នាងពៅ ក៏យកសំបកឈើចំលែកទាំងនេះបួងសួងថា "ប្រសិនបើសំបកឈើនេះពិតជារបស់ទិព្វពូកែស័ក្តិសិទ្ធិមែននោះ សូមឱ្យខ្ញុំទំពាព្រួសទៅលើសាកសពនេះបាននរស់ឡើងវិញដូចសត្វទាំងពីរអម្បាញ់មិញនេះផង"។

Neang Pov picked up the strange barks and prayed, "If the barks are sacred thing, then once I chew them and spit on the body, the body will come to life again like the miracle happening to the snake."




បន់ស្រន់ចប់ នាងក៏ទំពាសំបកឈើហើយព្រួសទៅលើផ្ទៃមុខ និងស្នាមរបួស ស្រាប់តែជាសះស្បើយដឹងខ្លួនឡើងវិញមែន។ ឃើញដូច្នេះ **នាងពៅ** ត្រេកអរខ្លាំងណាស់ សើចផងយំផងអោបប្តីជាទីស្រលាញ់របស់នាង ហើយក៏នាំគ្នាត្រឡប់មកផ្ទះវិញ។

Completing her praying, she chewed the barks and spat on the face and the wound of the body. The wound did heal quickly and her husband did come to life again. Seeing that, Neang Pov was so delighted; she laughed and cried, embracing her dear husband. Then, they returned home.



លុះដើរទៅដល់មាត់ស្ទឹងក៏មានទេវតាមួយអង្គតំណែងខ្លួនជាលោកសង្ឃចង់សាកចិត្ត **នាងពៅ** អុំទូកលឿនខ្លើតពីក្រោយ។ ប្តីក្រឡេកឃើញក៏និយាយទៅកាន់លោកសង្ឃនោះថា "ព្រះតេជគុណ ! សូមព្រះអង្គជួយចម្លងខ្ញុំព្រះករុណាទៅត្រើយម្ខាងផង"។ ព្រះសង្ឃមានពុទ្ធដីកាថា "ទូករបស់អាត្មាជិះបានតែពីរនាក់ប៉ុណ្ណោះ"។

When they arrived at a stream bank, a divinity in disguise as a Buddhist monk wanting to test Neang Pov rowed his boat so fast following them. Her husband turned around seeing the Buddhist monk and talked to him, "Venerable! Please help carry us to the opposite bank. " The monk said, "My boat can carry only two persons."




ព្រះសង្ឃមានពុទ្ធដីកាបន្តទៀតថា "ឥឡូវអីចេះចុះ អាត្មាជួយចម្លងម្ខាក់ម្តង តើញោមទាំងពីរអ្នកណាទៅមុន?" បុរសជាប្តីគិតថា "បើខ្ញុំទៅមុនប្រពន្ធនៅម្ខាក់ឯង មិនកើតទេ" គិតហើយគិតទៀតក៏សំរេចចិត្តឱ្យប្រពន្ធឡើងជិះទូកទៅជាមួយលោកសង្ឃឆ្លងទៅមុន។


The monk added, "Now, I help carry one of you each time, so between you two, who goes first?" The husband thought, "If I go first, my wife will be left alone. So it's impossible." After thinking, he let his wife get on the boat with the monk to cross the stream first.



ពេល **នាងពៅ** ឡើងទូកភ្លាមលោកសង្ឃក៏ប្រញាប់អុំទូកចេញទៅ ប៉ុន្តែមិនមែនឆ្លងទៅត្រើយម្ខាងនោះទេ គឺទៅតាមបណ្តោយទឹកស្ទឹងយ៉ាងលឿន។ ឃើញដូច្នេះបុរសជាប្តីគិតថា "ពុទ្ធោអើយ ! ខ្ញុំចាញ់បោកបញ្ឆោតលោកសង្ឃទៀតហើយ" គាត់ឈរសំឡឹងមើលប្រពន្ធដោយការអស់សង្ឃឹមយ៉ាងខ្លាំង។



Soon after Neang Pov got on the boat, the monk quickly rowed his boat away. However, he did not row across towards the opposite bank; instead, rowing his boat along the stream water current very fast. Seeing that, her husband thought, "God! Once again, I was deceived by the monk." He stood watching his wife with deep despair.




និយាយពីលោកសង្ឃដែលជាទេវតាតំណែងខ្លួនវិញ លុះអុំទូកឆ្ងាយទៅៗ ក៏ជប់ដើមម៉ាក់ប្រេងម៉ាក់ព្រាងមួយដើមមានផ្លែទុំក្រហមលឿងពាសពេញដើមក្បែរមាត់ស្ទឹង។ ពេល **នាងពៅ** ក្រឡេកឃើញក៏និយាយទៅកាន់ព្រះសង្ឃថា "ព្រះតេជគុណ ! ខ្ញុំព្រះករុណាចង់ទទួលទានផ្លែឈើនោះណាស់"។

About the monk who was the divinity in disguise, after rowing the boat away for quite long distance, he cast his magic to create a Mak Preng Mak Praing tree full of ripe red, yellow fruits growing near the stream. Neang Pov saw the tree and talked to the monk, "Venerable! I would really like to eat those fruits."


លោកសង្ឃឮភ្លាមក៏មានពុទ្ធដីកាថា "ចាំអាត្មាឡើងបេះឱ្យញោមស្រីចុះ" ថាហើយលោកសង្ឃអង្គនោះក៏វាត់កន្ទុយក្បិនឡើងបេះផ្លែឈើនោះភ្លាម **នាងពៅ** បន្តទៀតថា "ខ្ញុំព្រះករុណាចង់បានផ្លែមួយដែលខ្ពស់ជាងគេនោះ" ព្រះសង្ឃក៏ឡើងទៅបេះតាមដៃដែលនាងបានចង្អុលបង្ហាញ។

Hearing that, soon the monk said, "I climb to pick those fruits for you." Then, the monk rolled up the robe part between his legs and tucked in at his back waist and climbed to pick the fruits immediately. Neang Pov continued, "I want that fruit which stays the highest," so the monk climbed to pick the fruit at which she was pointing.




ឃើញឱកាសល្អដូច្នេះ **នាងពៅ** ក៏ច្រានទូកចេញចោលលោកសង្ឃនោះភ្លាម។ នាងខំអុំទូកត្រឡប់ទៅរកប្តីវិញ ប៉ុន្តែនៅពេលទៅដល់នាងពុំបានឃើញប្តីរបស់នាងឡើយ ឃើញតែស្នាមជានជើងធាក់ដីផុងបន្សល់ទុកជាច្រើនកន្លែងប៉ុណ្ណោះ។

Seeing good opportunity, Neang Pov immediately pushed the boat off and rowed it away without the monk. She tried to row the boat back to meet her husband. However, after arriving, she did not see her husband. She saw only many footprints in the soil.




នាងនឹកអាណិតប្តីខ្លាំងពេក ក៏ដាច់ចិត្តស្លៀកពាក់ជាមនុស្សប្រុសដើរស្វែងរកប្តីបន្តទៅទៀត។ នាងធ្វើដំណើរចេញពីភូមិមួយចូលភូមិមួយក៏ទៅដល់ផ្ទះមហាសេដ្ឋីដែលពួកគេកំពុងធ្វើបុណ្យសពកូនស្រីដែលត្រូវពស់ចឹកស្លាប់។

She felt so pity on her husband that she decided to disguise herself as a man to seek her husband. She walked through a village to another, and finally she arrived at a very wealthy man's house. They were holding the funeral for their dead daughter who had passed away because of fatal snake bite.




នាងពៅ ក៏សុំអង្វរអ្នកយាមទ្វារដើម្បីចូលទៅមើលសពកូនស្រីរបស់លោកមហាសេដ្ឋីដោយនាងអះអាងថា "បើសិនលោកអោយខ្ញុំចូលទៅប្រហែលជាខ្ញុំអាចជួយសង្គ្រោះនាងឱ្យរស់ឡើងវិញបាន" គ្រាន់តែគេឮសំដីនាងភ្លាម គេក៏ព្រមឱ្យនាងចូលទៅ។

Neang Pov begged the gatekeeper to let her enter and see the very wealthy man's dead daughter by saying, "If you let me enter, I might be able to make her come into life again." Soon after hearing her speech, the gatekeeper let her enter.




ពេលទៅដល់កន្លែងតំកល់សព **នាងពៅ** ក៏យកសំបកឈើទិព្វមកទំពាហើយ ព្រួសទៅលើស្នាមពស់ចឹក និងព្រួសទៅលើខ្លួនប្រាណដែលមានស្នាមជាំខ្មៅក៏ ប្រែជាស្រស់ថ្លាហើយនាងក៏បានដឹងខ្លួនឡើងវិញបើកភ្នែកស្ទុះងើបឡើងភ្លែតទៅ អោបឪពុករបស់នាង លោកសេដ្ឋីសប្បាយចិត្តរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។

When reaching the body-keeping place, she took out the sacred barks to chew and spat on the wound of snake bite and on the bruise parts of the body. The bruise parts turned to normal color, and she became alive again. She opened her eyes and jumped up to embrace her father. The wealthy man was totallydelighted.




ដោយសារតែឃើញ **នាងពៅ** ជួយសង្គ្រោះកូនស្រីឱ្យរួចផុតពីសេចក្តីស្លាប់ ហើយគេមានរូបរាងស្អាតសង្ហាក៏លើកកូនស្រីអោយទៅ **នាងពៅ** ហើយប្រគល់ទ្រព្យសម្បត្តិទាំងអស់ទៅឱ្យកូនទាំងពីរជាអ្នកកាន់កាប់។

Because Neang Pov had saved his daughter's life and was also handsome, the wealthy man decided to marry his daughter to Neang Pov and gave all the property to both of them.




លុះពេលរៀបការបានបីបួនថ្ងៃ កូនស្រីសេដ្ឋីនឹកឆ្ងល់ក្នុងចិត្តថា "ប្តីរបស់ខ្ញុំ តាំងពីរៀបការរួចមកគាត់សំរាន្តគ្រែផ្សេងគ្នា ហើយមិនព្រមដោះមួកចេញពីក្បាលសោះ ថែមទាំងមានទឹកមុខក្រៀមក្រំស្រពាប់ស្រពោនទៀតផង" ពេលនោះនាងក៏សួរទៅប្តីថា "បងសម្លាញ់ ! តើបងមានរឿងអ្វីទៅអូនអាចជួយបងបានដែរឬទេ?"

Three or four days after the marriage, the wealthy man's daughter wondered, "Since our marriage day, my husband has slept on a separate bed and hasn't agreed to take off his hat. Moreover, he has had sad face." So she asked her husband, "Do you have any problems, my darling? Could I help you?"



នាងពៅ ឆ្លើយឡើងថា "បងចង់ធ្វើបុណ្យដាក់ទានដល់អ្នកក្រីក្រខ្លះ តើអូនគិតយ៉ាងណាដែរ?" ប្រពន្ធក៏យល់ស្របតាមគំនិតប្តីហើយសង់រោងធ្វើបុណ្យដាក់ទានចំនួន៧យប់៧ថ្ងៃ។ **នាងពៅ** បានសរសេរអក្សរខាងលើដែលមានអត្ថន័យថា "បែកគ្នានៅតាមមាត់ស្ទឹង ព្រោះចាញ់បោកបញ្ឆោតលោកសង្ឃ"។

Neang Pov answered, "I want to hold a ceremony, giving alms to the poor. What do you think about this idea?" Neang Pov's wife agreed to the idea. They installed the ceremonial marquee for offering alms to the poor for 7 days and nights. Neang Pov display a sign hung above the marquee which read that, "Being apart from each other at the stream bank because being deceived by the monk."




លុះធ្វើបុណ្យដាក់ទានបានចំនួន៦ថ្ងៃទៅហើយ នៅតែមិនឃើញប្តីមកទៀត **នាងពៅ** អស់សង្ឃឹមជាខ្លាំងក៏ចូលសម្រាកក្នុងផ្ទះបាត់ទៅ។ ដល់ថ្ងៃទី៧ក៏មានបុរសម្នាក់ដើរមកដល់រោងបុណ្យហើយងាកមើលឃើញអក្សរក៏យំសោករហូតដល់សន្លប់បាត់ទៅ។ អ្នកបំរើឃើញក៏រត់ទៅប្រាប់ម្ចាស់ហើយក៏នាំគ្នាមកមើល។


After 6 days of alms-giving ceremony, she still had not seen her husband, so she felt hopeless and went to rest in the house. On the 7th day, a man arrived at the ceremonial marquee, read the sign letters, and then wept bitterly by rolling his body on the ground until becoming unconscious. A servant saw the fact and ran to tell the house's owners about that, and then they came to see the man.



នាងពៅ ឃើញប្តីដួលសន្លប់ក៏ស្រែកទ្រហោយំអោបប្តីរន្ធត់ក្នុងចិត្តក្រៃលែង។ ដល់ពេលប្តីនាងដឹងខ្លួនឡើងវិញ ប្តីប្រពន្ធទាំងពីរនាក់រៀបរាប់ប្រាប់រឿងរ៉ាវសព្វគ្រប់ទាំងអស់ដល់កូនស្រីសេដ្ឋីឱ្យបានយល់។

Neang Pov saw her husband lie unconscious, so she wailed, hugging her husband with strong feeling. After her husband became conscious, the spouses told everything to the wealthy man's daughter.





កូនសេដ្ឋីស្តាប់ឮអស់ហើយក៏និយាយទៅកាន់ **នាងពៅ** ថា "មិនអីទេ បងជាអ្នកមានគុណដែលសង្គ្រោះជីវិតខ្ញុំឱ្យរស់ឡើងវិញ ខ្ញុំនឹងនៅជាមួយបងស្រីទុកដូចជាបងប្អូនបង្កើតរបស់ខ្ញុំទៅចុះ"។ ចាប់តាំងពីពេលនោះមកប្តីប្រពន្ធ **នាងពៅសក់ក្រអូប** និងកូនស្រីសេដ្ឋីរស់នៅជាមួយគ្នាយ៉ាងសុខសាន្ត។ **ចប់**

ចំណេះវិជ្ជា ជាទ្រព្យជាប់នឹងត្រាណា

After listening to everything, the wealthy man's daughter talked to Neang Pov, "No, problem, I am indebted to you since you have made me become alive again. I will live with you like my sibling." From that time on, Fragrant-Haired Neang Pov along with her husband and the wealthy man's daughter live together in harmony. **The End**

Your Knowledge is your forever property.

រក្សាសិទ្ធគ្រប់យ៉ាងដោយ Reading Book

-បោះពុម្ពលើកទី១ ៣០០០ច្បាប់ ខែ កក្កដា ឆ្នាំ២០០៧

-បោះពុម្ពលើកទី២ ៥០០០ច្បាប់ ខែ មករា ឆ្នាំ២០០៨

-បោះពុម្ពលើកទី៣ ៥០០០ច្បាប់ ខែ មករា ឆ្នាំ២០១០

-Fist Edition 3000 Copies July 2007

-Second Edition 5000 Copies January 2008

-Third Edition 5000 Copies January 2010